មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) កាលពីថ្ងៃទី ០១-០២ ខែវិច្ឆិកា ឆ្នាំ ២០០៨ បានរៀបចំសំវាទមួយស្តីអំពី ប្រសិទ្ធិភាពនៃការនិយាយជាសាធារណៈនៅសណ្ឋាគារកាំបូឌីយ៉ាណា ដែលមានអ្នកចូលរួមជាកសិករសរុបចំនួន ២៧ នាក់ (ស្ត្រី ៦ នាក់) និងសម្របសម្រួលដោយបណ្ឌិត **យ៉ង សាំងកុមារ** លោក **ឃឹម សុផាណ្ណា** លោក **ប៉ាន សុភាព** និងលោក **តាត់ សុខ**។ គោលបំណងសំខាន់របស់សំវាទ គឺដើម្បីពង្រឹងការនិយាយ និងទំនាក់ទំនងរវាងគ្នាឱ្យកាន់តែប្រសើរឡើង។ វិធីសាស្ត្រសំខាន់ៗនៅក្នុងសំវាទនេះមានដូចជាៈ ការឈរនិយាយលើវេទិកាឱ្យអ្នកចូលរួមមើលឃើញមួយជំហរខ្លួន ការនិយាយដោយឈរនៅពីក្រោយតុវេទិកា ការអង្គុយនិយាយនៅនឹងតុវេទិកាកិត្តិយស ថតវីដីអូរ ចាក់សកម្មភាពដែលបានថតដោយប្រើ LCD និងធ្វើការឆ្លុះបញ្ចាំងជាដើម ។ល។

បើតាមប្រសាសន៍របស់បណ្ឌិត **យ៉ង សាំងកុមារ** ដើម្បីនិយាយឱ្យបានល្អត្រូវគិតទៅលើៈ កាយវិការទឹកមុខ សំលេង និងខ្លឹមសារ ចំណុចចាប់ផ្តើម និងបញ្ចប់នៃការនិយាយ ។

ដោយឡែកដើម្បីបង្កើនជំនាញក្នុងការដឹកនាំគ្រប់គ្រង យើងត្រូវបង្កើនជំនាញទូទៅទាក់ទងនឹងសង្គម ក្នុងនោះមានជំនាញ ៥ ដែលយើងត្រូវយកចិត្តទុកដាក់ៈ

- ការអាន : អានឱ្យបានច្រើន ដើម្បីបង្កើនចំណេះដឹងទូទៅ
- សរសេរ : ហាត់សរសេរ ដើម្បីបង្កើនជំនាញក្នុងការគិត និងវិភាគ
- និយាយ : ធ្វើយ៉ាងណាឱ្យគេស្តាប់យើង ហើយធ្វើតាមគំនិតរបស់យើង
- ស្តាប់ : អ្នកស្តាប់ដ៏ល្អ គឺអាចចាប់យកនូវចំណុចសំខាន់ដែលគេនិយាយ និងឆាប់យល់
- គណនាលេខ : ការវាងវៃក្នុងការគណនា ។